# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីពាក្យព្រះពុទ្ធសាសនា សម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិ

**web site: hoksavann.org**

ថ្ងៃទី៦ មីនា ២០០៥

ពាក្យថា <ទិដ្ឋិ> ស្មើគ្នានឹងពាក្យថាទស្សនៈ ប្រែថាការយល់ឃើញ ហើយប្រកាន់ជឿហៅថាលទ្ធិ ។ <ទិដ្ឋិ> នេះជាពាក្យកណ្តាល បើដាក់ < សម្មា> ខាងដើម ជា <សម្មាទិដ្ឋិ> ប្រែថាការយល់ត្រូវ បើដាក់ <មិច្ឆា> ខាងដើម ជា <មិច្ឆាទិដ្ឋិ> ប្រែថា ការយល់ខុស ។ ធម្មជាតិរបស់មនុស្ស តែងតែមានគំនិតយល់បែបណាមួយទៅលើបញ្ហាមួយ ទៅតាមឧបនិស្ស័យនិងការអប់រំរបស់ខ្លួន ហើយបើយល់បែបណាហើយ តែងតែប្រព្រឹត្តធ្វើអំពើបែបនោះ ។ មគ្គទី១ក្នុងបញ្ហាមគ្គទាំង៨គឺ សម្មាទិដ្ឋិ ប្រែថាការយល់ច្បាស់ក្នុងអរិយសច្ច៤គឺ ទុក្ខសច្ច សេចក្តីសុខបានដល់ការកើតមាននៃខន្ធ៥ ត្រូវកំណត់ដឹង, សមុទយសច្ច ហេតុដែលនាំឲ្យកើតទុក្ខត្រូវលះបង់, និរោធសច្ច ការរំលត់ទុក្ខបានដល់ព្រះនិព្វាន ត្រូវធ្វើឲ្យជាក់ច្បាស់, មគ្គសច្ច បានដល់មគ្គមានអង្គ៨ ត្រូវចំរើនឲ្យកើតឡើង ការឃើញអរិយសច្ច៤នេះ ឈ្មោះថាការឃើញត្រូវជាសម្មាទិដ្ឋិ ។ ការឃើញអរិយសច្ច៤នេះ ដោយសារការពិចារណាជាវិបស្សនានូវសេចក្តីពិត លក្ខណៈបីយ៉ាងនៃខន្ធ៥គឺ ខន្ធ៥មានលក្ខណៈមិនទៀងជាទុក្ខ និងជាអនត្តាពុំមានខ្លួន ។ ការពិចារណាឃើញសភាពពិតដូច្នេះ ឈ្មោះថាជាការយល់ត្រូវ ។ ក្នុងកុសលកម្មបថទី១០ ដែលជាវិន័យរបស់ឧបាសកឧបាសិកាមានឈ្មោះថា សម្មាទិដ្ឋិ និងនៅក្នុងបុញ្ញកិរិយាវត្ថុ១០យ៉ាងមានឈ្មោះថាទិដ្ឋុជុកម្ម ប្រែថា ធ្វើទិដ្ឋិឲ្យត្រង់គឺជឿកម្មនិងផលរបស់កម្ម ធ្វើល្អបានល្អធ្វើអាក្រក់បានអាក្រក់, ជឿការត្រាស់ដឹងរបស់ព្រះពុទ្ធ, ជឿព្រះធម៌ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ថាជាធម៌ដឹកនាំអ្នកប្រតិបត្តិ ឲ្យចេញចាកទុក្ខពិតមែន, ជឿព្រះសង្ឃជាភេទបរិសុទ្ធប្រតិបត្តិដ៏ប្រពៃពិតមែនទាំងអស់នេះចាត់ជាការធ្វើការយល់ឃើញត្រឹមត្រូវតាមសេចក្តីពិត ។ សម្មាទិដ្ឋិកាឃើញត្រូវនិងសម្មាសង្កប្បោ ការត្រិះរិះត្រូវ គឺត្រិះរិះមិនព្យាបាទមិនចង់បានទ្រព្យសម្បត្តិអ្នកដទៃ, ត្រិះរិះចេញចាកកាមទាំងពីរនេះសង្គ្រោះចូលក្នុងបញ្ញា ។ ពេលដែលព្រះអង្គចំរើនវិបស្សនាបាមសំរេចញាណណាមួយ ហៅថាអាសវក្ខយញ្ញាណ ដែលប្រែថាប្រាជ្ញាឃើញអរិយសច្ច៤ ដែលធ្វើឲ្យអាសវៈកិលេសនៃព្រះអង្គអស់ទៅបាន ដោយសារការយល់ត្រូវ គឺសម្មាទិដ្ឋិនេះឯង ។ ជនដែលមានគំនិតជាសម្មទិដ្ឋិ គឺកល្យាណបុថុជ្ជន និងសោតាបន្នបុគ្គល រហូតដល់ព្រះអរហន្ត ។

ចំណែកពាក្យថា មិច្ឆាទិដ្ឋិ ប្រែថាការយល់ខុស គឺឃើញប្រាសចាកសេចក្តីពិត ។ ក្នុងសុត្តន្តបិដកនៃគម្ពីរព្រះពុទ្ធសាសនាមាននិយាយអំពីទិដ្ឋិការយល់ខុសមានរហូតដល់៦២ប្រការ ដែលមានសំដែងក្នុងសូត្រមួយឈ្មោះព្រហ្មជាលសូត្រ ។ ទិដ្ឋិ៦២នេះព្រះអង្គបានបំប្រួញនូវគំនិតរបស់មនុស្សសត្វដែលយល់ខុស, គឺសត្វណាមានគំនិតយ៉ាងណា ក៏បញ្ញត្តិនូវទិដ្ឋិយ៉ាងនោះ ដូចជាបញ្ញាតថា ម្តាយឪពុកគ្មានគុណ លោកនេះទៀងខ្លះមិនទៀងខ្លះ, បរលោកគ្មានជាដើម ទាំងអស់នេះចាត់ជាគំនិតយល់ខុស ។ មានទិដ្ឋិយល់ខុសពីរយ៉ាងគឺ សស្សតទិដ្ឋិយល់ថា មានធម្មជាតិម្យ៉ាងនៅក្នុងខ្លួនមនុស្សសត្វ ដែលហៅអាត្មនជាភាសាសំស្រ្កឹត ឯបាលីថាអាត្មា ឬព្រលឹងវិញ្ញាណពុំចេះរលត់ បើទោះបីរូបត្រូវរលត់ទៅក៏ដោយក៏ធម្មជាតិនេះពុំរលត់ដែរ ។ ការយល់ខុសមួយទៀតគឺ ឧច្ឆេទទិដ្ឋិយល់ខុសថាគ្មានហេតុបច្ច័យសំរាប់បន្តផលមួយទៀតទេ ។ ក្រៅពីនោះមានការយល់ខុស៣យ៉ាងទៀត គឺអហេតុកទិដ្ឋិ បដិសេធហេតុ គឺផលដែលកើតឡើង គ្មានហេតុណាមួយបង្កើតឡើងទេ គឺកើតឡើងដោយចៃដន្យ អកិរិយទិដ្ឋិ បដិសេធកម្ម គឺអំពើដែលធ្វើគ្មានបង្កើតជាផលឡើយ, នត្ថិកទិដ្ឋិ បដិសេធទាំងហេតុទាំងកម្ម គឺបដិសេធទាំងពីរ ។ ព្រះពុទ្ធសំដែងថា សត្វលោកបើពុំទាន់ឃើញសច្ចធម៌គឺអរិយសច្ច៤ ដែលជាធម៌ចេញចាកទុក្ខទេ សត្វលោកនៅតែវង្វេងកើតស្លាប់ក្នុងវដ្តសង្សារជានិច្ច ។ ប្រៀបដូចជាមនុស្សងងឹតភ្នែកពីកំណើត រមែងដើរខុសផ្លូវ ពុំអាចដើរត្រូវផ្លូវ ទៅកាន់គោលដៅរបស់ខ្លួនបានឡើយ ។ យ៉ាងណាមិញ មនុស្សដែលមានអវិជ្ជាបិទបាំង រមែងពុំឃើញសភាពពិតនៃព្រះធម៌ គឺអរិយសច្ច៤ឡើយ ។ កាលណាមនុស្សមានមិច្ឆាទិដ្ឋិការយល់ខុស តែងតែប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ ដែលផ្តល់ផលមកវិញជាទុក្ខ ។

ដើម្បីកំចាត់បង់មិច្ឆាទិដ្ឋិការយល់ខុស ឲ្យកើតមានសម្មាទិដ្ឋិការយល់ត្រូវ ត្រូវអនុវត្តតាមចក្កធម៌៤ប្រការគឺ ១-សប្បុរិសូបសំសេវៈ សេពគប់សប្បុរស, ២- សទ្ធម្មស្សវនៈ ស្តាប់ពាក្យប្រៀនប្រដៅរបស់លោក, ៣- យោនិសោមនសិការៈ ធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា គឺពិចារណាឲ្យយល់ធម៌, ៤- ធម្មានុធម្មប្បដិបត្តិ ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ គឺប្រតិបត្តិឲ្យត្រឹមត្រូវតាមផ្លូវធម៌ ។៚